# ព្រះរាជក្រម

នស/រកម/១២១៧/ ០៤១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ទទួល
លេខ.........
ថ្ងៃទី.........ឆ្នាំ.........ម៉ោង.........
បញ្ជូនទៅ.........

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១៦

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥។ ការអនុវត្តនេះ សម្រេចបានលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោម៖

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ | ឆ្នាំ២០១៦ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = (I.១ + II.១) | ១៧ ៦១២ ៤៧៧,០ | ១៨ ៥១៥ ៧០៧,៩ | ១០៥,១% | +៩០៣ ២៣០,៩ |
| សរុបចំណាយ = (I.២ + II.២) | ១៧ ៥៤៤ ៤៧៧,០* | ១៦ ៩២៧ ៥៤៥,៤ | ៩៦,៥% | -៦១៦ ៩៣១,៦ |
| អតិរេកនៃថវិកា | +៦៨ ០០០,០ | +១ ៥៨៨ ១៦២,៥ | ២ ៣៣៥,៥% | +១ ៥២០ ១៦២,៥ |
| I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់ធនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | ១៣ ៧៤១ ១២៧,០ | ១៤ ៦៨៤ ៤៥៧,៧ | ១០៦,៩% | +៩៤៣ ៣៣០,៧ |
| • ចំណូលចរន្ត | ១៣ ៤០៧ ២៦៣,០ | ១៤ ២៧៧ ៦២២,៦ | ១០៦,៥% | +៨៧០ ៣៥៩,៦ |
| • ចំណូលមូលធន | ៣៣៣ ៨៦៤,០ | ៤០៦ ៨៣៥,១ | ១២១,៩% | +៧២ ៩៧១,១ |
| + ចំណូលមូលធនក្នុងប្រទេស | ១៣០ ៨៦៤,០ | ១១៩ ៨៩៩,៧ | ៩១,៦% | -១០ ៩៦៤,៣ |
| + ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២០៣ ០០០,០ | ២៨៦ ៩៣៥,៤ | ១៤១,៣% | +៨៣ ៩៣៥,៤ |
| I.២.ចំណាយថវិកា | ១៣ ៦៧៣ ១២៧,០* | ១៣ ០៩៦ ២៩៥,២ | ៩៥,៨% | -៥៧៦ ៨៣១,៨ |
| • ចំណាយចរន្ត | ១១ ២៣៨ ៩៨៩,០* | ១០ ៨៧៦ ៣៨៩,០ | ៩៦,៨% | -៣៦២ ៦០០,០ |
| • ចំណាយមូលធន | ២ ៤៣៤ ១៣៨,០ | ២ ២១៩ ៩០៦,២ | ៩១,២% | -២១៤ ២៣១,៨ |
| II.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៨៧១ ៣៥០,០ | ៣ ៨៣១ ២៥០,២ | ៩៩,០% | -៤០ ០៩៩,៨ |
| II.១.ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៨៧១ ៣៥០,០ | ៣ ៨៣១ ២៥០,២ | ៩៩,០% | -៤០ ០៩៩,៨ |
| II.២.ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |

*តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន៨២ ០០០លានរៀល ដោយយោងការធ្វើនិយ័តការូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។



**មាត្រា២ ..**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង"**ក**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ចំណាយថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង"**ខ**" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦: ចំពោះចំណូលថវិកាត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង"**ក**" និងចំពោះចំណាយថវិកាត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង"**ខ២**" ដូចមានភ្ជាប់ជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា៣ ..**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ សម្រេចបានលទ្ធផលដូចតទៅៈ

- ច្បាប់ហិរញ្ញវត្ថុ........................................ ១៣ ៧៤១ ១២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន......................... ១៤ ៦៨៤ ៤៥៧,៧ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុចំនួន........................................ ៩៤៣ ៣៣០,៧ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅៈ

១. ចំណូលចរន្ត
- ច្បាប់ហិរញ្ញវត្ថុ........................................១៣ ៤០៧ ២៦៣,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន......................... ១៤ ២៧៧ ៦២២,៦ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.............................. ៨៧០ ៣៥៩,៦ លានរៀល។

២. ចំណូលមូលធន
- ច្បាប់ហិរញ្ញវត្ថុ..........................................៣៣៣ ៨៦៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.............................. ៤០៦ ៨៣៥,១ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន.............................៧២ ៩៧១,១លានរៀល។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១៣០ ៨៦៤,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១១៩ ៨៩៩,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ១០ ៩៦៤,៣ លានរៀល។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ..............................................២០៣ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ២៨៦ ៩៣៥,៤ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន...................... ៨៣ ៩៣៥,៤ លានរៀល។

**មាត្រា៤ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ......................................... ១៣ ៦៧៣ ១២៧,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១៣ ០៩៦ ២៩៥,២ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុចំនួន..............................................៥៧៦ ៨៣១,៨ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ..............................................១១ ២៣៨ ៩៨៩,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន...........................១០ ៨៧៦ ៣៨៩,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ៣៦២ ៦០០,០ លានរៀល។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ.......................................... ២ ៤៣៤ ១៣៨,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ២ ២១៩ ៩០៦,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ២១៤ ២៣១,៨ លានរៀល។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ.......................................... ១ ៩២៥ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែងបានចំនួន.......................... ១ ៧៥៦ ៨៥៩,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន.......................... ១៦៨ ១៤០,៤ លានរៀល។